# ការតម្រូវនៃកម្មវិធី CAL-LEARN

| |
|---|
| កាលបរិច្ឆេទ : |
| ឈ្មោះសំណុំរឿង : |
| ឈ្មោះអ្នកចុះឈ្មោះ : |
| លេខសំណុំរឿង : |
| ឈ្មោះអ្នកកាន់សំណុំរឿង : |
| លេខទូរស័ព្ទ : |

## សេចក្តីប្រកាសនេះជំរាបអំពីការតម្រូវនៃកម្មវិធី

### តើកម្មវិធី Cal-Learn នេះមានន័យយ៉ាងណាចំពោះលោកអ្នក

ពីព្រោះតែលោកអ្នកត្រូវបានចុះឈ្មោះឱ្យចូលរួមជាមួយកម្មវិធី Cal-Learn (កម្មវិធីសិក្សាអប់រំនៃរដ្ឋកាលីហ្វ័រនីញ៉ាជួយចំពោះឪពុកម្តាយដែលមិនទាន់ពេញវ័យដែលទទួលជំនួយចំពោះគ្រួសារមានកូនក្នុងបន្ទុក (Aid to Families with Dependent Children ឬ AFDC)) :

- លោកអ្នកបានតម្រូវឱ្យទៅសាលារៀនដោយពេញពេលជាមូលដ្ឋានដើម្បីទទួលសញ្ញាបត្រមធ្យមសិក្សា ឬសញ្ញាបត្រដូចគ្នានេះ ។
- លោកអ្នកត្រូវបានតម្រូវឱ្យចូលរួមរហូតទាល់តែលោកអ្នកមានអាយុ១៩ឆ្នាំ លើកលែងតែលោកអ្នកត្រូវបានគេលើកលែងឱ្យ ។
- បើសិនជាលោកអ្នកចូលអាយុ១៩ឆ្នាំនៅពេលដែលលោកអ្នកនៅក្នុងកម្មវិធី Cal-Learn ហើយលោកអ្នកមិនទាន់បញ្ចប់សញ្ញាបត្រមធ្យមសិក្សា ឬសាលាដូចគ្នានេះ លោកអ្នកប្រហែលជាអាចបន្តចូលរួមនៅក្នុងកម្មវិធីនេះ រហូតទាល់តែលោកអ្នកមានអាយុ២០ឆ្នាំ ។
- លោកអ្នកនឹងត្រូវបានផ្តល់ឱ្យនូវឱកាសមួយ ដើម្បីជួយឱ្យលោកអ្នកបង្កើតជាគ្រោងការនៃសំណុំរឿងរបស់លោកអ្នក ដោយគិតបញ្ចូលទាំងកាលវិភាគបណ្ណរាយការណ៍សំរាប់ដាក់ស្នើ ។
- លោកអ្នកត្រូវបានតម្រូវឱ្យដាក់ស្នើបណ្ណរាយការណ៍ ឬសេចក្តីរាយការណ៍អំពីការចំរើនទៅឱ្យអ្នកចាត់ចែងលើសំណុំរឿងរបស់លោកអ្នក ។
- លោកអ្នកអាចទទួលប្រាក់រង្វាន់បន្ថែមរហូតដល់ទៅចំនួន១០០ដុល្លារ បួនដងក្នុង១ឆ្នាំ ចំពោះការទទួលចំណាត់ថ្នាក់C ឬប្រសើរជាង នៅលើបណ្ណរាយការណ៍ ។ លោកអ្នកអាចទទួលការធ្វើទណ្ឌកម្មរហូតដល់ទៅចំនួន១០០ដុល្លារ បួនដងក្នុង១ឆ្នាំ ចំពោះការទទួលចំណាត់ថ្នាក់ទាបជាងD ។
- លោកអ្នកអាចទទួលប្រាក់រង្វាន់បន្ថែមរហូតដល់ទៅ៥០០ដុល្លារ នៅពេលទទួលសញ្ញាបត្របញ្ចប់ការសិក្សា ។

ខណ្ឌនឹងផ្តល់កិច្ចជួយផ្នែករៀបចំលើសំណុំរឿងដើម្បីជួយលោកអ្នកក្នុងផ្នែក :

- បង្កើតជាកាលវិភាគបណ្ណរាយការណ៍ ។
- បង្កើតជាគ្រោងការផ្នែកសិក្សាអប់រំមួយដើម្បីជួយលោកអ្នកឱ្យទទួលសញ្ញាបត្រមធ្យមសិក្សា ឬសញ្ញាបត្រដូចគ្នានេះ ។
- ត្រួតពិនិត្យលើការរីកចំរើនរបស់លោកអ្នក និងជួយលោកអ្នកធ្វើការផ្លាស់ប្តូរជាចាំបាច់ណាទៅលើកម្មវិធីសាលារៀនរបស់លោកអ្នក ។
- ផ្តល់នូវការណែនាំឱ្យបានទទួលកិច្ចជួយត្រឹមត្រូវក្នុងសហគមន៍ ។
- ធ្វើឱ្យប្រាកដថាលោកអ្នកយល់អំពីការតម្រូវនៃកម្មវិធីCal-Learn និងផលវិបាកនៃការមិនធ្វើតាមការតម្រូវនៃកម្មវិធី ។

លោកអ្នកអាចទទួលប្រាក់បង់ឱ្យសំរាប់ការចំណាយលើថ្លៃថែរក្សាក្មេង យានដឹកនាំ និងការចំណាយទាក់ទងទៅនឹងការសិក្សាអប់រំ បើសិនជាបានត្រូវការ ។

គឺជាការទទួលខុសត្រូវរបស់លោកអ្នកដើម្បីប្រាប់អ្នកចាត់ចែងលើសំណុំរឿងរបស់លោកអ្នក បើសិនជាលោកអ្នកផ្លាស់ប្តូរផ្ទះ ប្តូរកិច្ចថែរក្សាក្មេង ឬត្រូវការកិច្ចជួយផ្គត់ផ្គង់ដទៃទៀត ឬមានបញ្ហាដើម្បីបំពេញតាមការតម្រូវរបស់កម្មវិធី ។

នៅមុនពេលយើងបន្ថយប្រាក់ជំនួយរបស់លោកអ្នកសំរាប់ការមិនធ្វើឱ្យមានការចំរើនគួរជាទីពេញចិត្តនៅសាលា គេនឹងផ្តល់ឱកាសជូនលោកអ្នកដើម្បីថ្លែងថាមកពីហេតុអ្វីបានជាលោកអ្នកមិនធ្វើតាម ។ បើសិនជាលោកអ្នកមានហេតុផលត្រឹមត្រូវមួយ ប្រាក់ជំនួយរបស់លោកអ្នកនឹងមិនត្រូវបានគេបន្ថយទេ ។

### ការលើកលែង

លោកអ្នកត្រូវបានចុះឈ្មោះឱ្យចូលរួមជាមួយកម្មវិធី Cal-Learn ។ ឪពុកម្តាយដែលមានអាយុមិនទាន់ពេញវ័យអាចត្រូវបានគេលើកលែង បើសិនជាគាត់ :

- មានជម្ងឺ របួស ឬរូបរាងកាយមិនអាចទៅសាលារៀនបាន ។
- ត្រូវបានបណ្តេញចេញពីសាលារៀន ហើយមិនអាចរៀបចំឱ្យមានការចុះឈ្មោះចូលរៀនជាមួយសាលារៀនដទៃទៀតបាន ។
- មិនអាចទទួលកិច្ចថែរក្សាក្មេង ឬយានដឹកនាំ ។
- ប្រាក់បង់សំរាប់ថែរក្សាកូនចិញ្ចឹមនៃកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (California Work Opportunity and Responsibility to Kids) គឺត្រូវបានផ្តល់ឱ្យក្នុងនាមនៃក្មេងអាយុមិនទាន់ពេញវ័យ ។

### ការពន្យារពេល

ឪពុកម្តាយជាក្មេងអាយុមិនទាន់ពេញវ័យអាចត្រូវបានគេពន្យារពេលឱ្យ បើសិនជាគាត់ :

- ត្រូវការកិច្ចជួយផ្គត់ផ្គង់ ឬកិច្ចចាត់ចែងលើសំណុំរឿង ដែលមិនមានជាបណ្តោះអាសន្ន ។
- មានសេចក្តីត្រូវការជាពិសេសមួយដែលបានបញ្ឈប់ឪពុកម្តាយជាក្មេងអាយុមិនទាន់ពេញវ័យមិនឱ្យបំពេញតាមការតម្រូវនៃកម្មវិធី ហើយដែលសេចក្តីត្រូវការពិសេសមិនអាចបំពេញឱ្យបាន ។
- វេជ្ជបណ្ឌិតបានឱ្យពេលសំរាកមួយរយៈដើម្បីឱ្យបានជាស្រួលបន្ទាប់ពីការសំរាលកូនរួចមក ។

អ្នកណាម្នាក់ដែលត្រូវបានពន្យារពេលឱ្យ នៅតែជាអ្នកចូលរួមជាចាំបាច់ក្នុងកម្មវិធី Cal-Learn ។ បើសិនជាលោកអ្នកមានលក្ខណៈដូចមូលហេតុដែលបានចុះសំរាប់ការលើកលែង ឬពន្យារពេលឱ្យពីកម្មវិធី Cal-Learn លោកអ្នកនៅតែត្រូវបានតម្រូវឱ្យទៅសាលារៀន ។ ច្បាប់សិក្សាអប់រំនៃរដ្ឋកាលីហ្វ័រនីញ៉ាផ្នែក 48200 តម្រូវថាលោកអ្នកត្រូវទៅសាលារៀន ។

លោកអ្នកមានសិទ្ធិស្នើសុំឱ្យមានការលើកលែងពីកម្មវិធី Cal-Learn ឬស្នើសុំកិច្ចជួយដូចជាកិច្ចថែរក្សាក្មេង និងយានដឹកនាំ ឬស្នើសុំកិច្ចជួយដទៃទៀតដែលបានផ្តល់ឱ្យដោយកម្មវិធី Cal-Learn ។ លោកអ្នកអាចស្នើសុំអ្នកចាត់ចែងលើសំណុំរឿងរបស់លោកអ្នកដោយទូរស័ព្ទ ឬដោយផ្ទាល់ ឬលោកអ្នកអាចស្នើសុំជាការសរសេរ ។